# បទពិសោធន៍ចិញ្ចឹម និងទាក់ទាញសត្វប្រចៀវ



លោកពូ គឹមសេង និងកន្លែងចិញ្ចឹមប្រចៀវរបស់គាត់

ប្រចៀវជាសត្វស្លាបម្យ៉ាងដែលមានក្លិនស្អុយ ប៉ុន្តែវាក៏ជាសត្វមានប្រយោជន៍ម្យ៉ាងដែរ គឺវាអាចស៊ីសត្វល្អិតចង្រៃមួយចំនួន និងលាមករបស់ប្រចៀវផ្តល់ជីជាតិដ៏សំខាន់ដល់ការលូតលាស់របស់ដំណាំគ្រប់ប្រភេទ ។ ដោយមើលឃើញនូវសារៈប្រយោជន៍បែបនេះ លោកពូ **ភេង គឹមសេង** រស់នៅភូមិអូរតាប៉ោង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិសាត់ គាត់មានចំណាប់អារម្មណ៍ចិញ្ចឹមសត្វប្រចៀវ ។ ការចិញ្ចឹមនេះបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៨២ ដែលកាលណោះប្រចៀវមានត្រឹមចំនួន ១០០ ក្បាល ប៉ុណ្ណោះ ។ បច្ចុប្បន្ន ប្រចៀវគាត់កើនបាន ចំនួន ៥-៦ ម៉ឺនក្បាល ។ បទពិសោធន៍ចិញ្ចឹមប្រចៀវនេះគាត់ចេះពីឪពុកម្តាយគាត់តៗគ្នាមក ។

## ១.ការផ្សាំងសត្វប្រចៀវ

មុនចាប់ផ្តើមចិញ្ចឹម គាត់សង្កេតមើលតើភូមិណាមួយ ឬ កន្លែងណាមួយមានសត្វប្រចៀវរស់នៅ ទើបគាត់ធ្វើការផ្សាំងឲ្យសត្វប្រចៀវស្គាល់កន្លែងសិន ប៉ុន្តែបើកន្លែងនោះពុំមានសត្វប្រចៀវរស់នៅទេ យើងមិនអាចធ្វើសំបុកបានទេ ។ ការផ្សាំងនេះ គាត់បានកាប់ស្លឹកត្នោតឲ្យធ្លាក់សំយាកចុះមកក្រោមទាំងស្លឹកស្រស់ ឬ ងាប់ ធ្វើយ៉ាងណាឲ្យមានភាពស៊ុបទ្រុប ដើម្បីទាក់ទាញឲ្យសត្វប្រចៀវមករស់នៅ ។

## ២.ការរៀបចំធ្វើសំបុក



ផ្ទាកសញ្ញាសំគាល់ទីកន្លែងចិញ្ចឹម និងអភិរក្សសត្វប្រចៀវ

លោកពូបានរៀបចំជាស៊ុម ដើម្បីចំលងពីដើមដែលកាប់ធ្វើជំរកមុនឲ្យវាមករស់នៅ ។ ស៊ុមអាចហៅបានថា ជាសំបុកធ្វើអំពីឈើ ដែលមានបណ្តោយ ២ ម៉ែត្រ និងទទឹង ២ ម៉ែត្រ ។ ស៊ុមនេះគាត់បានដំឈើប្រទាក់គ្នា ដើម្បីពាក់ធាងត្នោតធ្វើជាជំរក ។ ទំហំនេះសម្រាប់សំបុកតូចពាក់នៅលើដើមឈើ ១ ដើម និងប្រើធាងត្នោតអស់ចំនួន ១៦០ ធាង ។ ចំពោះសំបុកធំសម្រាប់ដើមឈើ ២ ដើម ដែលនៅជិតគ្នា (ចន្លោះ ២-៣ ម៉ែត្រ ពីគ្នា) ។ សំបុកធំមានទំហំទទឹង ២,៣ ម៉ែត្រ បណ្តោយ ៦ ម៉ែត្រ ក្នុងស៊ុមមានដំឈើប្រទាក់ក្រឡាគ្នា ដូចស៊ុមតូចដែរ ។ ចំពោះឈើដែលយកមកធ្វើស៊ុម គាត់

ជ្រើសរើសឈើល្អ (ខ្លឹម) ដើម្បីកុំឲ្យចាប់ពុកប្រើបានយូរ (ប្រចៀវអាចរស់នៅបាន ៣~៤ ឆ្នាំ) ។ ចំពោះដើមឈើដែលត្រូវធ្វើជាសំបុក លោកពូបានមានប្រសាសន៍ថា អាចជ្រើសរើសយកដើមឈើប្រភេទអ្វីក៏បានដែរដូចជា ត្នោត ដូង ។ល។ ឲ្យតែយើងបានដឹងថាមានប្រចៀវរស់នៅ ។ សំបុកតូចគាត់ចំណាយប្រាក់អស់ពី ១៥~២០ ម៉ឺនរៀល ។ ចំពោះសំបុកធំចំណាយអស់ ៣០~៤០ ម៉ឺនរៀល ។

## ៣.ការសង្កេតទៅលើលក្ខណៈរស់នៅរបស់ប្រចៀវ

លោកពូបានឲ្យដឹងថាប្រចៀវដែលគាត់ចិញ្ចឹមជាប្រចៀវស៊ីសត្វល្អិត វារស់នៅជាហ្វូង ចេញដំណើររកស៊ីជាហ្វូង និងចាំសំបុករបស់វា លុះត្រាតែសំបុកស្អុះស្អាប់ មានដូចជា ស្រមើរ និងសង្កើចទើបវាលែងនៅមួយរយៈផ្លាស់ទៅនៅសំបុកផ្សេង លុះសំបុកចាស់លែងមានសត្វល្អិតយាយីរ វាត្រឡប់មករស់នៅវិញ ។ ដូច្នេះហើយ ទើបគាត់ធ្វើសំបុកច្រើនទុកឲ្យប្រចៀវផ្លាស់លំនៅ (សំបុកគាត់ទាំងអស់ ១៩) ។

ម៉ោងប្រមាណ ៥~៦ (ថ្ងៃលិច) ប្រចៀវចាប់ចេញរកស៊ី ម៉ោងប្រហែល ៩~១០ យប់ វាហើរចូលទ្រនិវិញជាបន្តបន្ទាប់រហូតដល់ជិតភ្លឺ ទើបហើរចូលសំបុកអស់ ។ នៅពេលជិតចេញដំណើររកស៊ី មានមេខ្យល់វាចំនួន ៤~៥ ក្បាលចេញពីសំបុកមកថ្ងៃលមើលជុំវិញ ២~៣ ដង មើលអាកាសធាតុ និងស្ថានភាពតើអាចចេញដំណើរបានឬទេ បន្ទាប់មកទើបវាសំរេចចិត្តចេញពីសំបុកទាំងហ្វូង ។

ក្នុង ១ ឆ្នាំ សត្វប្រចៀវមានកូនតែម្តង (នៅខែមេសា) មេ ១ អាចកើតបានកូន ២ ។ ល្បឿនដែលវាហើររកចំណី ៣២ គីឡូម៉ែត្រ ក្នុង ១ ម៉ោង ។ សត្វប្រចៀវ ១ ក្បាល អាចផ្ទុកចំណីបាន ១ ភាគ ៣ នៃទំងន់ខ្លួនរបស់វា ។ លោកពូបានសង្កេតឃើញថា នៅខែរងា ឬ រដូវភ្លៀង ប្រចៀវពុំសូវមានអាចម៍ទេ ព្រោះពុំសូវមានសត្វល្អិតស៊ី ម្យ៉ាងទៀតអាកាសធាតុពុំសូវល្អ វាសំងំក្នុងសំបុកមិនចេញរកចំណីទេ ពេលមេឃស្រឡះ ទើបវាចេញរកចំណី ។ រីឯសំបុកដែលនៅឆ្ងាញពីលំនៅដ្ឋានពេកប្រចៀវមិនសូវរស់នៅទេ ព្រោះច្រើនមានអ្នករំខាន ដូចជាក្មេងបាញ់លេង ឬ មានសត្វស្ទាំងមកចាប់ស៊ីគ្មានញញើត ។ កន្លែងដែលប្រចៀវមករស់នៅច្រើនដោយសារវាមានភាពកក់ក្តៅ (គ្មានអ្នករំខាន ឬ សំលាប់វា) ។

## ៥.ការប្រមូលអាចម៍ប្រចៀវ



ការបង្ហាញអំពីសំបុកតូច និងទ្រុងដាក់លាមកប្រចៀវ

នៅពេលភ្លឺឡើង (ព្រលឹម) ប្រចៀវជុះអាចម៍ពេញក្រោមដើមឈើដែលបានធ្វើសំបុក ។ នៅក្រោមដើមឈើដែលធ្វើសំបុកនោះ ត្រូវជំរះស្មៅជុំវិញគល់ ឈើឲ្យបានស្អាតចំងាយពីគល់ ២ ម៉ែត្រ ដើម្បីងាយស្រួលក្នុងការប្រមូលលាមកប្រចៀវ ។ ការបោសប្រមូលលាមកចាប់ផ្តើមនៅម៉ោង ១~២ ថ្ងៃត្រង់ ដើម្បីអោយលាមកស្ងួតស្រពាប់ (ស្ងួតខ្លាំងអស់ជាតិទឹកនោម) ។ តាមការប៉ាន់ប្រមាណរបស់លោកពូ សត្វប្រចៀវប្រហែល ជាង ១ ម៉ឺនក្បាល ប្រមូលលាមកបានពី ៦~៧ គីឡូក្រាម ក្នុង

១ ថ្ងៃ ។ ក្រោយពីប្រមូលហើយ គាត់យកទៅចាក់គរទុកនៅក្នុងរោងដីដែលមានតំបូលប្រក់ស្លឹក ជញ្ជាំងធ្វើពីឈើព័ទ្ធជុំវិញការពារកំដៅ និងភ្លៀង ។ នៅពេលគាត់ប្រមូលទុកជាគំនរបានច្រើន ទើបចាប់ផ្តើមច្រកចូលការុង ។ មួយការុងច្រកបានលាមកប្រចៀវសុទ្ធពី ៣០-៤០ គីឡូក្រាម និងលក់បានតំលៃ ៤ ម៉ឺនរៀល ក្នុង ១ ការុង ។

ក្រៅពីលាមកប្រចៀវដែលចិញ្ចឹមដោយខ្លួនឯងផ្ទាល់ លោកពូបានប្រមូលទិញពីអ្នកជិតខាងដែលចិញ្ចឹមប្រចៀវដែរនោះបន្ថែមទៀត ព្រោះគាត់អាចរកទីផ្សារលក់បានស្រួល ។ បច្ចុប្បន្ននៅភូមិរបស់គាត់មានកសិករចំនួន ៧-៨ គ្រួសារ ដែលចិញ្ចឹមប្រចៀវដោយពិតប្រាកដ និងមានអង្គការដានីដា ជួយគាំទ្រក្នុងការអភិរក្សសត្វប្រចៀវ ។

## ៦.ការយកដីលាមកប្រចៀវទៅប្រើប្រាស់លើដំណាំ

តាមបទពិសោធន៍របស់លោកពូបានឲ្យដឹងថា ដើម្បីយកលាមកប្រចៀវប្រើប្រាស់លើដំណាំឲ្យមានប្រសិទ្ធិភាព ត្រូវយកដីនោះទៅផ្សំឲ្យកាច់សិន ដោយលាយជាមួយលាមកសត្វផ្សេងៗ ។ គឺគាត់បានយកលាមកប្រចៀវ ១ ការ៉ុង (៣០-៤០ គីឡូក្រាម) លាយជាមួយលាមកគោ ១ រទេះ ប្របល់ចូលគ្នាឲ្យសព្វ រួចស្រោចទឹកឲ្យជោគ ទើបយកក្រណាត់កៅស៊ូគ្របអោយជិតរក្សាទុករយៈពេល ៥-៧ ថ្ងៃ ទើបយកទៅប្រើលើដំណាំ ។ ការធ្វើរបៀបនេះធ្វើឲ្យដីមានគុណភាពល្អ (ផុស) ដំណាំលូតលាស់ល្អជាងការប្រើដីលាមកប្រចៀវស្រស់ ។



សំបុកធំដែលចងភ្ជោបជាមួយដើមត្នោតពីរ នៅជិតគ្នា

## ៧.ចំណាប់អារម្មណ៍របស់លោកពូ គឹម សេង

ក្នុងការចិញ្ចឹម និងអភិរក្សសត្វប្រចៀវនេះ លោកពូមានចំណាប់អារម្មណ៍ថា ជាការងារមួយដែលអាចរកប្រាក់ចំណូលបានស្រួល មិនធ្វើឲ្យមានការខ្វាយខ្វល់ ឬ រវល់ច្រើនពេកទេ ក្រៅពីការធ្វើសំបុក និងប្រមូលលាមករាល់ថ្ងៃ ។ ម្យ៉ាងទៀតបានរួមចំណែកអភិរក្សសត្វប្រចៀវកុំឲ្យបាត់បង់ផង ព្រោះសត្វប្រចៀវមានប្រយោជន៍ជួយស៊ីសត្វល្អិត និងផ្តល់លាមកធ្វើជាជីដាក់ដំណាំ ។ គាត់ដឹងគុណដល់សត្វប្រចៀវ ព្រោះគាត់បានរស់ដោយសារសត្វប្រចៀវនេះ ។

សរុបមក កត្តាសំខាន់ក្នុងការចិញ្ចឹម និងទាក់ទាញឲ្យមានសត្វប្រចៀវមករស់នៅច្រើនមាន:

- សង្កេតមើលតំបន់ដែលមានសត្វប្រចៀវធ្វើការផ្សាំងឲ្យស្គាល់សំបុក
- កុំឲ្យមានការរំខានដល់ការរស់នៅរបស់ប្រចៀវ (កុំគប់ ឬ បាញ់សំបុក)
- នៅពេលធ្វើសំបុកថ្មីត្រូវយកស្លឹកចាស់ៗ ដែលវាធ្លាប់ជ្រកទៅបង្កប់ក្នុងសំបុកថ្មី ឬ ចាក់សំឡេងប្រចៀវយំឲ្យវាឮប្រចៀវ និងមករស់នៅច្រើន
- ធ្វើសំបុកឲ្យច្រើនទុកឲ្យប្រចៀវផ្លាស់លំនៅនៅពេលសំបុកចាស់ស្អុះស្អាប់ ។

**ពាន សុខា, ចាន់ សាវុន, និងគឹម សាន**